THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF ACADEMIC SERVICES**
440 North Broad Street
Suite 201
Philadelphia, PA 19130

ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០២៣

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា (SDP) សរសេរលិខិតដើម្បីទំនាក់ទំនងអំពីការផ្លាស់ប្តូរគោលការណ៍ដ៏សំខាន់ដែលធ្វើឡើងដោយ នាយកដ្ឋានអប់រំរដ្ឋផិនស៊ីលវេនញ៉ា (PDE) ដែលនឹងផ្តល់សេវាអប់រំបន្តដល់សិស្សដែលទទួលការអប់រំពិសេស។ ការផ្លាស់ប្តូរគោលការណ៍នេះនឹងផ្តល់ឱ្យសិស្សនូវសិទ្ធិទទួលការអប់រំជាសាធារណៈដែលសមរម្យដោយឥតគិតថ្លៃ (FAPE) ដោយសារពួកគេមានសិទ្ធិក្រោមច្បាប់សហព័ន្ធ។

ចាប់ផ្តើមប្រតិបត្តិនៅថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០២៣ សិស្សទាំងអស់ដែលមាន សិទ្ធិទទួលការអប់រំជាសាធារណៈដែលសមរម្យដោយឥតគិតថ្លៃ (FAPE) និងសិស្សទាំងអស់ដែលមានសិទ្ធិលើ សិទ្ធិ និងនីតិវិធីនៃការការពារសិទ្ធិក្រោមច្បាប់ស្តីពីការអប់រំសិស្សពិការ (IDEA) និង ជំពូក ១៤ នៃ មាត្រា ២២ នៃក្រមរដ្ឋផិនស៊ីលវេនញ៉ា អាចបន្តចុះឈ្មោះនៅសាលាសាធារណៈរហូតដល់ពួកគេមានអាយុ ២២ ឆ្នាំ។ នេះរាប់បញ្ចូលទាំងសិស្សដែលមានអាយុ ២១ ឆ្នាំ ហើយបានចាកចេញក្នុងអំឡុង ឬក្រោយ ឆ្នាំសិក្សា ២០២២-២០២៣។

ប្រសិនបើលោកអ្នកទទួលសារនេះ កូនរបស់លោកអ្នកមានសិទ្ធិ (ប៉ុន្តែមិនតម្រូវឱ្យ) ចុះឈ្មោះឡើងវិញ ឬបន្តចុះឈ្មោះនៅសាលារបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា រហូតដល់ថ្ងៃខួបកំណើតទី ២២ របស់ពួកគេ។ ឧទាហរណ៍ ប្រសិនបើសិស្សមានអាយុ ២២ ឆ្នាំនៅថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០២៣ ថ្ងៃចុងក្រោយនៃការចុះឈ្មោះរបស់ពួកគេនៅក្រសួងអប់រំគឺ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០២៣។

**<u>តើវិធីសម្រាប់ការចុះឈ្មោះកូនរបស់លោកអ្នកឡើងវិញគឺជាអ្វី</u>?**

- មាតាបិតា/អាណាព្យាបាល គួរតែចុះឈ្មោះកូនរបស់គាត់នៅសាលាដែលក្មេងបានទៅរៀនចុងក្រោយ។
- ដោយសារការវិវឌ្ឍនៃកន្លែង និងចំណុះនៅសាលា ក្រសួងអប់រំមិនអាចធានាថាសិស្សរបស់លោកអ្នកនឹងត្រូវបានចាត់តាំងនៅសាលាដែលពួកគេចុះឈ្មោះចុងក្រោយនោះទេ។ ប្រសិនបើគ្មានកន្លែងទំនេរនៅសាលាដែលក្មេងបានចុះឈ្មោះនាពេលថ្មីៗនេះទេ នាយកសាលា (ឬអ្នកតំណាង) នឹងទាក់ទងទៅនាយកផ្នែកអប់រំពិសេសរបស់បណ្តាញ ដើម្បីស្វែងរកកន្លែងចាត់តាំងជំនួសសម្រាប់សិស្ស។
- មាតាបិតា/អាណាព្យាបាល នឹងទទួលការបញ្ជាក់អំពីការចុះឈ្មោះក្នុងរយៈពេលសែសិបប្រាំបីម៉ោង។

សម្រាប់ព័ត៌មានលម្អិតបន្ថែមអំពីការផ្លាស់ប្តូរគោលការណ៍នេះ និងដើម្បីអានកំណត់ហេតុផ្លូវការពីនាយកដ្ឋានអប់

រំរដ្ឋផិនស៊ីលវេនញ៉ា សូមចូលទៅកាន់ គេហទំព័ររបស់ការិយាល័យសម្រាប់សិស្សដែលមានភាពផ្សេងៗគ្នា (Office of Diverse Learners website)។ ប្រសិនបើលោកអ្នកមាន សំណួរ/ការបារម្ភ អ្វីមួយ សូមទាក់ទង ការិយាល័យផ្តល់ការអប់រំពិសេស និងសិស្សដែលមានភាពផ្សេងៗគ្នា តាមរយៈលេខ (215) 400-4170។

ដោយសេចក្តីស្មោះស្ម័គ្រ

Sonya Berry, ប្រធានស្តីទី
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា
ការិយាល័យផ្តល់ការអប់រំពិសេស និងសិស្សដែលមានភាពផ្សេងៗគ្នា